# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីគុណសម្បត្តិនៃព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថនរោត្តម-សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលមិនយកអគ្គមហេសី

web site: hoksavann.org

ថ្ងៃទី៣០ ឧសភា ២០០៦

សូមកោតសរសើរព្រះមហាក្សត្រខ្មែរបច្ចុប្បន្ន ចំពោះចំណុចមួយ គឺការមិនយកអគ្គមហេសី ទោះបីមានមូលហេតុអ្វីក៏ដោយ ។ នេះជាគុណធម៌ដ៏សំខាន់ ដែលផ្ទុយពីព្រះមហាក្សត្រខ្មែរពីអតីតកាល ដែលមានអគ្គមហេសីរាប់មិនអស់ រហូតដល់បង្គាប់ឲ្យគេយកស្រីខ្មែរ ដែលមានរូបល្អនៅតាមខេត្ត យកមកថ្វាយធ្វើជាស្រីស្នំទៀតផង ។ មិនតែប៉ុណ្ណោះ អតីត:ព្រះមហាក្សត្រខ្មែរខ្លះ បានយកស្រីបរទេសមកធ្វើជាអគ្គមហេសី រហូតបាត់បង់ទឹកដី ដោយការល្មោភលោភលន់ក្នុងកាមនេះឯង។ ព្រះមហាក្សត្រខ្មែរបច្ចុប្បន្ន បើនៅតែរក្សាព្រះទ័យមិនយកអគ្គមហេសី ព្រះសង្ឃនិងប្រជាពលរដ្ឋខ្មែរ សូមអនុមោទនាត្រេកអរជាទីបំផុត ។

ព្រះពុទ្ធកាលនៅជាព្រះពោធិសត្វព្រះសិទ្ធត្ថ: ព្រះអង្គបានចាកចេញពីព្រះរាជវាំង ទៅបួសជាតាបសបុស្សី ដើម្បីស្វែងរកការត្រាស់ដឹងជាព្រះពុទ្ធ ដើម្បីរំដោះទុក្ខចេញពីការកើតចាស់ឈឺស្លាប់ ដោយព្រះអង្គឃើញទោសក្នុងកាមគុណ៥គឺ រូប សម្លេង ក្លិន រស សម្ផស្សនេះឯង ។ នៅក្នុងព្រះបរមរាជវាំង ព្រះពោធិសត្វសិទ្ធត្ថជាមកុដិរាជកុមារ បានទទួលការទំនុកបំរុងពីបិតា ដោយគ្រឿងសប្បាយក្នុងកាមសុខដូចជាស្រីស្នំក្រមការ ក្រៅពីព្រះអគ្គមហេសី គឺព្រះនាងពិម្ពា មានរបាំដូរ្យតន្ត្រី និងចំរៀងគ្រប់ប្រភេទ តែព្រះអង្គមិនជាប់ព្រះទ័យ ដោយព្រះអង្គយល់ថា កាមសុខនេះពុំស្ថិតស្ថេរឡើយ ដោយជរាព្យាធិមរណ: កំពុងមកដុតបំផ្លាញរាល់ថ្ងៃ ទីបំផុតរូបរាងកាយត្រូវរលាយ ។ កាលព្រះអង្គត្រាស់ជាព្រះពុទ្ធ ហើយសំដែងធម៌ទេសនាជាដំបូងប្រោសភិក្ខុ៥អង្គ ព្រះអង្គត្រាស់ថា កាមសុខល្លិកានុយោគ គឺការបណ្តោយចិត្ត

ឲ្យជាប់ជំពាក់ក្នុងកាមគុណា៥គឺ រូប សម្លេង ក្លិន រស សម្ផស្ស ជាធម៌របស់អ្នកស្រុក ជាធម៌របស់មនុស្សបុថុជ្ជន ពុំមែនជាធម៌របស់ព្រះអរិយបុគ្គលឡើយ ប្រព្រឹត្តទៅនាំឲ្យខ្សោយបញ្ញា ពុំអាចត្រាស់ដឹងបានឡើយ ។ ដូច្នេះ ព្រះពោធិសត្វឃើញទោសក្នុងកាមគុណា៥ ថាមានគុណតិច មានទោសច្រើន ធ្វើឲ្យអ្នកប្រព្រឹត្តមានកង្វល់ បិទបាំងបញ្ញាស្មារតី មិនឲ្យឃើញអរិយសច្ចៈ មានទុក្ខសច្ចៈជាដើមបានឡើយ ។ ក្នុងន័យនេះ គួរអ្នកដឹកនាំជាតិជាន់ខ្ពស់ មានព្រះមហាក្សត្រជាដើម បន្ថយការសប្បាយក្នុងកាមគុណា ឬលះបង់មិនប្រព្រឹត្តតែម្តង ដើម្បីធ្វើព្រះទ័យនិងចិត្តឲ្យបរិសុទ្ធ ដើម្បីដឹកនាំជាតិឲ្យមានប្រសិទ្ធិភាព ។ កាលពីសម័យបុរាណ អំណាចដឹកនាំរដ្ឋបានស្ថិតនៅលើព្រះមហាក្សត្រ ទើបតែសម័យក្រោយ អំណាចគ្រប់យ៉ាងបានស្ថិតនៅលើប្រជាពលរដ្ឋ ទើបនៅក្នុងទសពិធរាជធម៌១០យ៉ាង ដែលព្រះពុទ្ធបានសំដែងថ្វាយព្រះមហាក្សត្រឲ្យប្រតិបត្តិតាម មានភាពតឹងរ៉ឹងណាស់ ក្នុងទសពិធរាជធម៌មានកន្លែងខ្លះដូចព្រះវិន័យរបស់ព្រះសង្ឃ ។

ទាក់ទងនឹងកាមគុណា៥មានរូបជាដើម នៅក្នុងខទី៦នៃទសពិធរាជធម៌ គឺតបៈ ប្រែថា ការដុតកំដៅកិលេស បានដល់ព្រះមហាក្សត្រ ត្រូវកាន់ឧបោសថសីលតាមកាលកំណត់ ដើម្បីបន្ថយនូវកាមារម្មណ៍ គឺការបន្ថយនូវការសប្បាយក្នុង រូប សម្លេង ក្លិន រស និង សម្ផស្ស ឬផ្តាច់ចាកកាមក្នុងថ្ងៃឧបោសថនោះ (បើផ្តាច់បានរាល់ថ្ងៃរឹតតែប្រសើរណាស់ទៅទៀត) ព្រោះថា បើអ្នកដឹកនារដ្ឋជាន់ខ្ពស់សប្បាយក្នុងកាមខ្លាំងពេក នាំឲ្យរវល់ច្រើនក្នុងកាម ខាតពេលវេលាទៅបំពេញកិច្ចការរដ្ឋ ។

តាមព្រះរាជបន្ទូលរបស់ព្រះករុណាសម្តេចព្រះនរោត្តម-សីហនុ អតីតៈព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលទើបនឹងយាងមកពីសាធារណរដ្ឋប្រជាមានិតចិនថា វេជ្ជបណ្ឌិតចិនគេប្រាប់ថា ព្រះអង្គសប្បាយក្នុងការរាំច្រៀង ទើបមានព្រះជន្មវែង ។ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហេតុដែលនាំឲ្យមានអាយុវែង មានលក្ខណៈផ្ទុយពីវេជ្ជបណ្ឌិតចិន ព្រោះមនុស្សចាស់ កម្លាំងពលំទន់ខ្សោយ ខំសប្បាយដោយការច្រៀងរាំ នាំឲ្យមានអាយុខ្លីទៅវិញទេ ។ តាមធម៌ព្រះពុទ្ធ ហេតុដែលនាំឲ្យអាយុវែង ក្រៅពីជាតិមុនឬជាតិនេះ មិនបានសម្លាប់ជីវិតមនុស្សសត្វ មានធម៌៥ទៀតក្នុងបច្ចុប្បន្នជួយឧបត្ថម្ភឲ្យមានអាយុវែងគឺ ទី១-សប្បាយការី ប្រែថាធ្វើខ្លួនឲ្យសប្បាយ គឺមិនកើតទុក្ខពីអ្វីមួយ, ទី២- សប្បាយេ មត្តំ ជានាតិ ប្រែថាដឹងប្រមាណក្នុងការសប្បាយ ។ ពាក្យនេះមានន័យផ្ទុយពីពេទ្យចិន ដែលថាឲ្យរាំឲ្យច្រៀង ដើម្បីឲ្យមានអាយុវែង ។ ពាក្យព្រះពុទ្ធនេះបានន័យថា បើមានកម្លាំងខ្សោយ កុំខំរាំច្រៀង ធ្វើការឲ្យលើសកម្លាំង តែត្រូវធ្វើចិត្តឲ្យស្ងប់ ចាកកាមទាំង៥ មានការរាំការច្រៀងជាដើមនេះ ព្រោះចិត្តស្ងប់នាំឲ្យបានសុខ សរសៃប្រសាទមិនធ្វើការខ្លាំងនាំឲ្យមានអា-យុវែង ។ ទី៣- បរិណាតភោជី ប្រែថាបរិភោគអាហារល្មមភ្លើងធាតុធ្វើឲ្យរលួយស្រួល ។ ត្រង់នេះទាក់ទងនឹងធាតុក្នុងខ្លួននិងរបបអាហារ ខ្លះបរិភោគមិនបានជាគិត

ហាល់រហូតស្លាប់ ដោយធាតុក្នុងខ្លួន ជាពិសេសក្រពះខ្សោយ ។ ទី៤- កាលចារី ប្រែថា ដើរលេងក្នុងការគួរ គឺពេលវេលានិងទីកន្លែងគួរទៅ ព្រោះពេលខ្លះ ដូចពេលយប់ និងទីកន្លែងខ្លះ ដូចទីកន្លែងមានចោរលួចប្លន់ បើធ្វើដំណើរទៅអាចទទួលគ្រោះថ្នាក់ ។ ទី៥- ព្រហ្មចារី ប្រែថាប្រព្រឹត្តធម៌ប្រសើរមិនល្មោភក្នុងកាម ។ ត្រង់នេះទាក់ទងនឹងអ្នកមានប្រពន្ធ និងអគ្គមហេសីតែមួយ ដោយសន្តោសក្នុងកាម ឬបើមិនយកភរិយា មិនយកអគ្គមហេសី នាំឲ្យមានអាយុវែង ។ ផ្ទុយទៅវិញ អ្នកល្មោភក្នុងកាមបានសេចក្តីថា មានប្រពន្ធឬអគ្គមហេសីច្រើន នឹងមានអាយុខ្លី ។ អតីតៈព្រះមហាក្សត្រខ្មែរ មុននឹងយាងមកដល់ប្រទេសកម្ពុជាមានបន្ទូលថា ពេលមកដល់ប្រទេសកម្ពុជា ព្រះអង្គនឹងធ្វើពិធីជប់លៀងមួយ ដែលមានចូលរួមដោយមន្ត្រីរាជការគ្រប់ស្ថាប័ន ហើយស៊ីផឹករាំវែកមិននិយាយនយោបាយទេ ។ ការរាំវែកច្រៀងរាំជាអំពើរបស់មនុស្សសាមញ្ញ ចំណែកព្រះមហាក្សត្រជាបុគ្គលជាន់ខ្ពស់ ជាទីគោរពរបស់ពលរដ្ឋខ្មែរ គួរប្រែពិធីអបាយមុខនេះ ទៅជាពិធីបុណ្យអប់រំមនុស្សទៅវិញ ។ យ៉ាងណាមិញ គួរបង្វែពិធីនេះ ថាជាពិធីសួរសុខទុក្ខ គឺសួរសុខទុក្ខចំពោះកូនចៅគ្រប់ស្ថាប័ន ដែលព្រះករុណាសម្តេចបានឃ្លាតចេញមួយឆ្នាំហើយ ។ ក្នុងពិធីនោះ គួរនិមន្តព្រះសង្ឃមកអនុមោទនាត្រេកអរចំពោះការជួបជុំគ្នានេះ ហើយទទួលសីល ៥ពីលោក គឺគ្រប់ស្ថាប័នទាំងអស់ត្រូវរក្សាសីល៥ ហើយស្តាប់ឱវាទឬទេសនាពីព្រះសង្ឃ ដែលមានចំណេះខ្ពស់ខាងព្រះពុទ្ធសាសនា ។ បន្ទាប់មកគួរមានសុន្ទរកថា ឬសង្កថារបស់ព្រះមហាក្សត្រស្វាគមន៍សួរសុខទុក្ខកូនចៅអ្នកចូលរួមទាំងអស់ជាព្រះបន្ទូលស្និទ្ធស្នាល ពុំមែនជារឿងនយោបាយទេ ជាពិសេសអាចលើកយកធម៌របស់ព្រះពុទ្ធសាសនា មកបញ្ចូលក្នុងសុន្ទរកថា ដូចជាធម៌សាមគ្គី រក្សាពុទ្ធសាសនាជាសាសនារដ្ឋ រក្សាបូរណភាពទឹកដី រក្សាអធិបតេយ្យជាតិ រក្សាឯកភាពជាតិជាដើម ។ ត្រង់នេះ ដូចជាឪពុកឲ្យឱវាទកូនចៅ ។ ចប់បន្ទូលព្រះមហាក្សត្រអាចសោយព្រះក្រយាស្ងោយ ទទួលទានភោជនាហារជាមួយគ្នា ជៀសវាងតែការរាំវែកច្រៀងរាំប៉ុណ្ណោះ ព្រោះការច្រៀងរាំនេះ មិនសមក្នុងពិធីនេះទេ ។ បើអតីតៈព្រះមហាក្សត្រខ្មែរ បង្វែពិធីជប់លៀងច្រៀងរាំនេះ ឲ្យមកជាពិធីសួរសុខទុក្ខ បង្កើតបរិយាកាសបុណ្យទាន ពង្រឹងស្មារតីមនុស្សតាមផ្លូវព្រះពុទ្ធទៅវិញ ជាពិធីល្អជាង ។

សូមរំលឹកឡើងវិញ កាលអំឡុងឆ្នាំ១៩៨០ អតីតៈព្រះមហាក្សត្រខ្មែរព្រមទាំងសម្តេចព្រះអគ្គមហេសី បានចូលចាប់កុសលកសាងព្រះវិហារវត្តខ្មែរកាណាដា តាមមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ចំនួន២,០០០ដុល្លារអាមេរិក តាមរយៈទ្រង់ស៊ីសុវត្ថិ-សេរីរ័ត្ន ជាឯកអគ្គរាជទូតខ្មែរប្រចាំអង្គការសហប្រជាជាតិ នៅពេលនោះចំនួនជាង២០ឆ្នាំកន្លងមកហើយ ។ ដោយព្រះរាជកុសលដ៏ថ្លៃថ្លានេះ ជាថ្មីទៀត សូមថ្វាយព្រះពរ សូមព្រះករុណាសម្តេចនិងសម្តេចអគ្គមហេសី មានព្រះសុខភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ។

សូមកោតសរសើរម្តងទៀត ចំពោះព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម-សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលមិនយកព្រះអគ្គមហេសី ដែលហាក់ដូចជាមានតែមួយព្រះអង្គគត់ ក្នុងពិភពលោកចំពោះប្រវត្តិព្រះមហាក្សត្រដែលមិនយកអគ្គមហេសី ហើយព្រះមហាកសត្រ ដែលមានអគ្គមហេសីតែមួយមានចំនួនតិចណាស់ រហូតមកដល់សព្វថ្ងៃនេះ ព្រះមហាក្សត្រនៅលើពិភពលោកនៅមានចំនួនតិច ដោយព្រះអង្គសោយរាជ្យតែមិនកាន់អំណាច ។ គេតែងនិយាយថា ភរិយាជាទីប្រឹក្សារបស់ស្វាមី បើភរិយាមិនប្រកបដោយធម៌ នឹងឲ្យយោបល់ស្វាមីធ្វើអាក្រក់ ។ បើស្វាមីមានភរិយានិងស្រីល្អួចលាក់ច្រើនវិញ បើអ្នករាជការនឹងប្រព្រឹត្តអំពើពុករលួយ ហើយកើតអំពើហឹង្សា ដោយការច្រណែនរវាងប្រពន្ធចុងនិងប្រពន្ធដើម ។ បើព្រះមហាក្សត្រខ្មែរមិនយកអគ្គមហេសីវិញ នឹងរួចចាកបញ្ហាទាំងអស់នេះ ។ សូមថ្វាយព្រះពរចំពោះគុណសម្បត្តិនេះ ។៚